00219334

D 55/I/8

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 26 / Augt / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ**

សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៦)

**ចំពោះមុខ:**

**ចៅក្រម ប្រាក់ គីមសាន ប្រធាន**
**ចៅក្រម Rowan DOWNING**
**ចៅក្រម នេយ ថុល**
**ចៅក្រម Katinka LAHUIS**
**ចៅក្រម ហួត វុទ្ធី**

**កាលបរិច្ឆេទ:** **២៦ សីហា ២០០៨**

---

**សាធារណៈ:**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព**

---

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**

នួន ជា

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

លោក ហុង គីមសួន
លោក ឡោ ជុនធី
លោក នី ចាន់ឌី
គង់ ពិសី
Silke STUDZINSKY
យុង ផានិត

**សហមេធាវីការពារក្តី**

លោក សុន អារុណ
Michiel PESTMAN
Victor KOPPE

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 26 / Augt / 2008
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១
ទូរស័ព្ទ: (៨៥៥)-២៣-២១៩-៨១៤ ទូរសារ: (៨៥៥)-២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh

D55/I/8

០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៦)

**អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក"** ទទួលបានបណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ("បណ្តឹងឧទ្ធរណ៍") របស់លោក **នួន ជា** ("ជនត្រូវចោទ") ។

## ជំពូក ១ - សេចក្តីផ្តើម

១. នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ សហមេធាវីការពារក្តីរបស់ជនត្រូវចោទបានដាក់សំណើរបស់ខ្លួនជូនសហចៅក្រមស៊ើបអង្កេត ដើម្បីសុំឱ្យអង្គបុរេជំនុំជម្រះទទួលពាក្យសុំយកមកប្រកាសអំពីមោឃភាពនីតិវិធី ("ពាក្យសុំមោឃភាព")។

២. នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានលើកសំណើនេះចោល ហើយបានចេញដីកាបដិសេធសំណើសុំមោឃភាពនេះ ("ដីកា") ដែលបានដាក់នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៨។

៣. នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៨ សហមេធាវីការពារក្តីបានដាក់សារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួនជាភាសាអង់គ្លេស។ នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៨ បន្ទាប់ពីមានការបកប្រែរួច ក៏មានការជូនដំណឹងអំពីសារណាបណ្តឹងឧទ្ធរណ៍ជាភាសាខ្មែរ។

៤. នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានតបរបស់ខ្លួនចំពោះសារណាបណ្តឹងឧទ្ធរណ៍របស់លោក **នួន ជា** ដែលបានប្តឹងចំពោះដីកាបដិសេធសំណើសុំមោឃភាពកិច្ចស៊ើបសួរ ("សេចក្តីសន្និដ្ឋានតប")។

៥. មេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់សារណាតបឡើយ។

៦. នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានចេញដីកាកំណត់ថ្ងៃសវនាការគឺបានកំណត់បើកនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨។ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ ប្រធានអង្គ



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE ២

បុរេជំនុំជម្រះបានទទួលលិខិតមួយច្បាប់ពី លោក សុន អារុណ ដែលជាសហមេធាវីការពារក្ដីរបស់ជនត្រូវចោទ ដោយនៅក្នុងនោះបានជម្រាបលោកប្រធានថា សហមេធាវីការពារក្ដីអន្តរជាតិនឹងមិនមានវត្តមានចូលរួមក្នុងសវនាការនោះឡើយ។ ដោយផ្អែកលើព័ត៌មាននេះដែលលើកឡើងនៅក្នុងលិខិត អង្គបុរេជំនុំជម្រះបានចេញសេចក្ដីសម្រេចនៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០០៨ បន្តនីតិវិធី ដោយផ្អែកលើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ហើយលុបចោលសវនាការ។

៧. យោងតាមសេចក្ដីអញ្ជើញរបស់អង្គបុរេជំនុំជម្រះឱ្យដាក់សេចក្ដីសន្និដ្ឋានតប នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០០៨ សហមេធាវីការពារក្ដីបានគូសបញ្ជាក់ថា ខ្លួនមិនមានសេចក្ដីសន្និដ្ឋានតបបន្ថែមដាក់ជូនឡើយ។

## ជំពូក ២ - ភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍

៨. សហមេធាវីការពារក្ដីបានដាក់សារណាបណ្ដឹងឧទ្ធរណ៍របស់ខ្លួនជូនផ្ទាល់ទៅអង្គបុរេជំនុំជម្រះនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលវាផ្ទុយនឹងវិធាន ៧៥នៃវិធានផ្ទៃក្នុង ដោយក្នុងនោះចែងថា សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ ត្រូវដាក់ជូនក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត។ ប៉ុន្តែ ដោយហេតុថា សារណាបណ្ដឹងឧទ្ធរណ៍ត្រូវបានទទួលយកដោយក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះនៅពេលនោះ អង្គបុរេជំនុំជម្រះយល់ឃើញថា វិការៈលើបញ្ហាបច្ចេកទេសនេះ មិនគួរបង្កើតជាករណីដែលនាំដល់ការប្រកាសថា បណ្ដឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានឡើយ។

## ជំពូក ៣ - បណ្ដឹងឧទ្ធរណ៍

៩. នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្លួន សហមេធាវីការពារក្ដីស្នើសុំអង្គបុរេជំនុំជម្រះឱ្យទទួលយកពាក្យសុំមោឃភាពនេះមកធ្វើការជំនុំជម្រះ ស្នើសុំឱ្យធ្វើការវាយតម្លៃលើអង្គសេចក្ដីសារជាថ្មី ស្នើសុំឱ្យប្រកាសថាកិច្ចស៊ើបសួរដែលបានតវ៉ានេះមោឃៈ ហើយដោយសារមូលហេតុនេះ

00219337

D55/I/8



សហមេធាវីការពារក្ដីស្នើសុំឱ្យដកចម្លើយទាំងឡាយដែលពាក់ព័ន្ធចេញពីកំណត់ហេតុ។ ដោយសារករណីនេះ សហមេធាវីការពារក្ដីសន្និដ្ឋានថា ពាក្យសុំមោឃភាពនេះត្រឹមត្រូវតាមទម្រង់ និងមានហេតុផលគ្រប់គ្រាន់។[១]

១០. សហមេធាវីការពារក្ដីក៏បានស្នើសុំបន្ថែមដល់អង្គបុរេជំនុំជម្រះឱ្យធ្វើការបញ្ជាក់បញ្ហានីតិវិធីចំនួនពីរចំនុចៈ

(១) ការអនុវត្តនីតិវិធីនាពេលបច្ចុប្បន្នក្នុងការស្នើសុំមោឃភាពនីតិវិធីកិច្ចស៊ើបសួរដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ជាមួយនឹងច្បាប់កម្ពុជា។

(២) ចាត់ទុកថានីតិវិធីនៅក្នុងវិធានផ្ទៃក្នុងមានសុពលភាព តួនាទីដ៏ត្រឹមត្រូវរបស់សហចៅក្រមស៊ើបអង្កេត។

១១. សហព្រះរាជអាជ្ញាធ្វើការសន្និដ្ឋាននៅក្នុសេចក្ដីសន្និដ្ឋានតបរបស់ខ្លួនថា ការទាញអំណះអំណាងទាំងនេះចំពោះបញ្ហានីតិវិធីគួរត្រូវទាត់ចោល។

## ១. នីតិវិធីមោឃភាពនៅ អ.វ.ត.ក

១២. អង្គបុរេជំនុំជម្រះសង្កេតឃើញថា នីតិវិធីជាធរមាននៅ អ.វ.ត.ក បានទទួលការយល់ស្របពីអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជានៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣។ មាត្រា ១២ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង") ចែងថាៈ

> ១. នីតិវិធីត្រូវសមស្របជាមួយច្បាប់កម្ពុជា។ នៅពេលណាដែលច្បាប់កម្ពុជា ពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ ឬមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តន៍បទប្បញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងទៅនឹងភាពមិនសមស្របគ្នារវាងបទប្បញ្ញត្តិបែបនេះទៅនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។

---

[១] បណ្ដឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាពចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៨ D55/I/1 វាក្យខណ្ឌទី៣។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00219338

D55/I/8



២. អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយដែលកម្ពុជា គឺរដ្ឋហត្ថលេខីដែរ។ [...]

១៣. នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ កិច្ចប្រជុំពេញអង្គរវាងចៅក្រមជាតិនិងអន្តរជាតិបានអនុម័តវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក ហើយវិធានផ្ទៃក្នុងនេះបានចូលជាធរមាននៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៧ ដែលនៅក្នុងបុព្វកថាចែងថា:

" **អាស្រ័យហេតុនេះ** អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាបានអនុម័តវិធានផ្ទៃក្នុង ដូចខាងក្រោម ដែលមានគោលបំណងធ្វើការចងក្រងនូវនីតិវិធីជាធរមានរបស់កម្ពុជាសម្រាប់អនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ និង ដោយអនុលោមតាមមាត្រា ២០ថ្មី ២៣ថ្មី និង មាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា និង មាត្រា ១២-១ នៃកិច្ចព្រមព្រៀង អនុម័តវិធានមួយចំនួនបន្ថែមទៀត នៅពេលណាដែលច្បាប់កម្ពុជាជាធរមានពុំអាចដោះស្រាយបានចំពោះករណីពិសេសណាមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ ទាក់ទងទៅនឹងការបកស្រាយ ឬ ការអនុវត្ត ឬ ក៏ប្រសិនបើមានបញ្ហាពាក់ព័ន្ធទាក់ទងនឹងភាពសមស្របគ្នារវាងបទប្បញ្ញត្តិនៅក្នុងច្បាប់កម្ពុជាទៅនឹងនិយាមអន្តរជាតិ។"

១៤. ដូច្នេះ វិធានផ្ទៃក្នុងបង្កើតជាប្រព័ន្ធច្បាប់នីតិវិធីមួយដោយខ្លួនឯង ដែលពាក់ព័ន្ធនឹងកាលៈទេសៈពិសេសរបស់ អ.វ.ត.ក ហើយត្រូវបានអនុម័ត និងមានការយល់ស្របពីកិច្ចប្រជុំពេញអង្គនៃ អ.វ.ត.ក។ វិធានផ្ទៃក្នុងនេះមិនផ្ទុយនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឡើយ ប៉ុន្តែគោលបំណងរបស់ អ.វ.ត.ក ខុសគ្នាជាសំខាន់ពីដំណើរការសាមញ្ញរបស់តុលាការព្រហ្មទណ្ឌកម្ពុជា ដែលតម្រូវឱ្យ អ.វ.ត.ក មានប្រព័ន្ធមួយដែលមានលក្ខណៈពិសេស។ ដូច្នេះ វិធានផ្ទៃក្នុងជាលិខិតូបករណ៍ចំបង ដែលយើងគួរនឹងយកមកពិនិត្យមើល ក្នុងការកំណត់នីតិវិធីនៅចំពោះមុខ អ.វ.ត.ក ក្នុងករណីមានភាពខុសគ្នារវាងនីតិវិធីនៃវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

១៥. បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាគួរយកមកអនុវត្ត ក្នុងករណីមានបញ្ហាចោទណាមួយដែលវិធានផ្ទៃក្នុងមិនមានចែងតែប៉ុណ្ណោះ។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

00219339

D55/I/8



១៦. អង្គបុរេជំនុំជម្រះយល់ឃើញថា វិធានផ្ទៃក្នុងបានចែងយ៉ាងច្បាស់លាស់ និងគ្រប់គ្រាន់ចំពោះករណីមោឃភាពនីតិវិធី ហេតុដូច្នេះហើយវានៅជាធរមាន។ ភាគីណា ដែលយល់ឃើញថាផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធីមានមោឃភាព ត្រូវដាក់ពាក្យសុំដោយមានសម្អាងហេតុជូនសហចៅក្រមស៊ើបអង្កេតជាមុន ដោយស្នើសុំឱ្យពួកគាត់បញ្ជូនសំណើទៅឱ្យអង្គបុរេជំនុំជម្រះទទួលយករឿងក្តី។

១៧. ដោយសារមូលហេតុនេះហើយ អង្គបុរេជំនុំជម្រះមិនចាំបាច់ពិភាក្សាបន្ថែមលើសេចក្តីសន្និដ្ឋានរបស់សហមេធាវីការពារក្តីឡើយចំពោះចំនុចនេះ។

## ២. តួនាទីរបស់សហចៅក្រមស៊ើបអង្កេតចំពោះនីតិវិធីមោឃភាព

១៨. វិធាន ៧៦(២)នៃវិធានផ្ទៃក្នុង ចែងថា:

> ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ នៅពេលដែលភាគីទាំងឡាយយល់ឃើញថា មានផ្នែកណាមួយត្រូវបានចាត់ទុកជាមោឃៈ ភាគីនោះអាចដាក់ពាក្យសុំដោយបញ្ជាក់មូលហេតុទៅសហចៅក្រមស៊ើបអង្កេត ដើម្បីស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត ប្តឹងទៅអង្គបុរេជំនុំជម្រះស្នើសុំឱ្យធ្វើមោឃភាព។ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាដែលអាចជាការទទួលយក ឬ បដិសេធសំណើសុំភ្លាមៗតាមតែអាចធ្វើទៅបាន និងក្នុងគ្រប់ករណីទាំងអស់ត្រូវធ្វើឡើងមុនពេលចេញដីកាដំណោះស្រាយ។ ដីកាបែបនេះ គឺជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដោយអនុលោមតាមវិធានផ្ទៃក្នុងនេះ។

១៩. សហមេធាវីការពារក្តីសន្និដ្ឋានថា តួនាទីរបស់សហចៅក្រមស៊ើបអង្កេតដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងនៅក្នុងករណីនេះគឺមិនច្បាស់លាស់។ "លក្ខណៈវិនិច្ឆ័យចំពោះការទទួលយក ឬ បដិសេធពាក្យសុំរបស់ ក.ស.ច.ស មិនឃើញមានចែងនៅក្នុងវិធានផ្ទៃក្នុង។ [...] នៅក្នុងករណីនេះ យើងហាក់ដូចយល់ឃើញថា ក.ស.ច.ស គឺបំពេញតួនាទីដូចនឹង "អ្នកយាមទ្វារ" ដែលមានតួនាទីធ្វើការវាយតម្លៃតាមការមើលឃើញមួយភ្លែត ដោយពុំបានពិនិត្យស៊ីជម្រៅអំពីសុពលភាពនៃទម្រង់របស់ពាក្យសុំឡើយ។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

២០. នៅក្នុងសេចក្ដីសន្និដ្ឋានតប សហព្រះរាជអាជ្ញាសន្និដ្ឋានថា"នៅពេលដែលអ្នកតាក់តែងវិធានទាំងនេះបានចាត់តាំងមុខងារ *ក្នុងការចេញដីកា* ទៅឱ្យសមត្ថកិច្ចណាមួយរបស់តុលាការដូចជា សហចៅក្រមស៊ើបអង្កេតនេះ គឺពួកគេរំពឹងចង់ឱ្យសមត្ថកិច្ចរបស់តុលាការនេះគិតគូរធ្វើបែបនោះ តាមរយៈការដាក់ពាក្យសុំតាមផ្លូវតុលាការ និងការបញ្ជាក់ពីមូលហេតុ។[...] ចំពោះសមត្ថកិច្ចរបស់តុលាការ (ដូចជា អ.ប.ជ) នេះ ដើម្បីអនុវត្តការពិនិត្យឡើងវិញលើបណ្ដឹងឧទ្ធរណ៍របស់ខ្លួនឱ្យបានត្រឹមត្រូវ ជាសំខាន់នោះនៅក្នុងដីកាកោះហៅសួរដេញដោលត្រូវមានការផ្ដល់មូលហេតុ ជាពិសេសគឺនៅពេលត្រូវអនុវត្តនូវឆន្ទានុសិទ្ធិតាមផ្លូវតុលាការរបស់ខ្លួន។ [...] ការអានរួមបញ្ចូលជាមួយគ្នានូវវិធាន ៧៦.១ និងវិធាន ៧៦.២ ក៏អាចនឹងនាំទៅរកការធ្វើសេចក្ដីសន្និដ្ឋាន អ្នកតាក់តែងវិធានចង់ឱ្យសហចៅក្រមស៊ើបអង្កេតបញ្ជាក់មូលហេតុអំពីការមិនព្រមបញ្ជូនពាក្យសុំឱ្យធ្វើមោឃភាពនេះ។ វិធានបានតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតដាក់ពាក្យសុំ ដោយបញ្ជាក់មូលហេតុមួយអនុលោមតាមវិធាន ៧៦.១ នៅពេលពួកគេធ្វើសំណើសុំឱ្យធ្វើមោឃភាពនេះ ដោយផ្អែកលើពាក្យបណ្ដឹងរបស់ពួកគេផ្ទាល់។ ដោយការប្រៀបប្រដូចដីកាបង្គាប់មួយដែលបញ្ជូនពាក្យសុំរបស់ភាគីមួយទៅ អ.ប.ជ ក៏គួរបានបញ្ជាក់មូលហេតុដូចគ្នាដែរ ដើម្បីជូនព័ត៌មានដល់ អ.ប.ជ ឱ្យបានជ្រាបអំពីការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតចំពោះកិច្ចស៊ើបសួរដែលមានការតវ៉ាដេញដោលនោះ។"

២១. អង្គបុរេជំនុំជម្រះយល់ឃើញថា "សេចក្ដីសម្រេចទាំងអស់របស់តុលាការតម្រូវឱ្យផ្ដល់សម្អាងហេតុ ដោយសារវាជាបទដ្ឋានអន្តរជាតិ"។[២] ដូច្នេះ ដីការបស់សហចៅក្រមស៊ើបអង្កេត ស្ដីពី

---

[២] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្ដីសង្កេតទូទៅ មាត្រា ១៤ វាក្យខណ្ឌទី៤៩។ សូមអាន លិខិតឆ្លើយឆ្លងលេខ ៩០៣/១៩៩៩ *Van Hulst ទល់នឹង ហូឡង់ដ៍* ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៤ វាក្យខណ្ឌទី៦(៤)។ លិខិតឆ្លើយឆ្លងលេខ ៧០៩/១៩៩៦ *Bailey ទល់នឹង ចាម៉ៃកា* ថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៩៩ វាក្យខណ្ឌទី៧(២)។ លិខិតឆ្លើយឆ្លងលេខ ៦៦៣/១៩៩៥ *Morrison ទល់នឹង ចាម៉ៃកា* ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ វាក្យខណ្ឌទី៨(៥)។ *រដ្ឋអាជ្ញា ទល់នឹង Milutinovic* រឿងក្ដីលេខ IT-99-37-AR65(3) សេចក្ដីសម្រេចបដិសេធសំណើរបស់ Milutinovic ស្នើសុំការអនុញ្ញាតប្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៣ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ វាក្យខណ្ឌទី២២។ *រដ្ឋអាជ្ញា ទល់នឹង Furundzija* IT-95-17/1-A អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សេចក្ដីសម្រេច ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ វាក្យខណ្ឌទី៦៩។ តុលាការអ៊ឺរ៉ុបផ្នែកសិទ្ធិមនុស្ស រឿងក្ដី *Suominen ទល់នឹង ហ្វាំងឡង់ដ៍* ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៣ វាក្យខណ្ឌទី ៣៦។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. / C.E.T.C.

00219341

D55/I/8

០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៦)

សំណើសុំឱ្យអង្គបុរេជំនុំជម្រះទទួលយករឿងក្តីមកជំនុំជម្រះ នោះដាច់ខាតត្រូវរៀបរាប់ហេតុផលចំពោះការទទួល ឬការបដិសេធសំណើនេះ។

២២. វិធាន ៤៨នៃវិធានផ្ទៃក្នុងចែងអំពីមូលដ្ឋាននៃការបដិសេធឬការទទួលយកពាក្យសុំមោឃភាព:

> កិច្ចស៊ើបសួរ ឬ កិច្ចរបស់អង្គជំនុំជម្រះអាចត្រូវបានចាត់ទុកជាមោឃៈតែចំពោះករណីមិនគោរពវិធាន បញ្ញត្តិដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំប៉ុណ្ណោះ។

២៣. សហចៅក្រមស៊ើបអង្កេត ត្រូវធ្វើការពិនិត្យពាក្យសុំនេះដោយផ្អែកលើមូលដ្ឋានចំនួនពីរ: (១) វត្តមាននៃមោឃភាពនីតិវិធី។ និង (២) នៅពេលមានមោឃភាពនីតិវិធីមែននោះ នឹងមានការរំលោភសិទ្ធិរបស់ភាគីដែលធ្វើពាក្យសុំ។ ចំពោះបណ្តឹងឧទ្ធរណ៍នៅចំពោះមុខខ្លួននាពេលបច្ចុប្បន្ននេះ អង្គបុរេជំនុំជម្រះត្រូវពិនិត្យមើលសារជាថ្មីនូវការពិនិត្យស្រាវជ្រាវរបស់សហចៅក្រមស៊ើប។

## ជំពូក ៤ - ពាក្យសុំមោឃភាព

### ១. ការទទួលយកពាក្យសុំ

២៤. វិធាន ៧៦(៤)នៃវិធានផ្ទៃក្នុងចែងថា:

> អង្គបុរេជំនុំជម្រះអាចប្រកាសថា ពាក្យសុំមោឃភាពនេះមិនអាចទទួលយកបាន ប្រសិនបើពាក្យសុំមិនបានបង្ហាញហេតុផលគ្រប់គ្រាន់ ពាក្យសុំនេះមានពាក់ព័ន្ធជាមួយដីកាដែលត្រូវប្តឹងឧទ្ធរណ៍ ឬ ពាក្យសុំនេះគ្មានមូលដ្ឋានច្បាស់លាស់។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះបិទផ្លូវប្តឹងឧទ្ធរណ៍។ នៅពេលដែលអង្គបុរេជំនុំជម្រះបដិសេធបណ្តឹងសុំមោឃៈភាព សំណុំរឿងត្រូវបញ្ជូនត្រឡប់ទៅឲ្យសហចៅក្រមស៊ើបអង្កេតវិញ។

២៥. នេះមានន័យថា អង្គបុរេជំនុំជម្រះអាចប្រកាសមិនទទួលយកពាក្យសុំមោឃភាព ក្នុងករណីដែលពាក្យសុំ: (១) មិនបានបង្ហាញហេតុផលគ្រប់គ្រាន់ (២) ពាក់ព័ន្ធជាមួយដីកាដែលត្រូវប្តឹងឧទ្ធរណ៍ ឬ(៣) គ្មានមូលដ្ឋានច្បាស់លាស់។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE ECCC CETC

២៦. ពាក្យសុំមោឃភាពរបស់សហមេធាវីការពារក្តី លើកបញ្ហាចោទពាក់ព័ន្ធទៅនឹងសុពលភាពនៃការបោះបង់សិទ្ធិមានមេធាវីរបស់ជនត្រូវចោទក្នុងពេលបង្ហាញខ្លួនលើកដំបូង និងសវនាការតទល់គ្នា ព្រមទាំងកំណត់ហេតុនៃការសួរយកចម្លើយជនត្រូវចោទចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ ២០០៧ ("កំណត់ហេតុនៃការសួរយកចម្លើយ")។

២៧. នៅក្នុងដំណាក់ការនីតិវិធីមុនគឺនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៧ សហមេធាវីការពារក្តីជាតិបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន របស់សហចៅក្រមស៊ើបអង្កេត។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ សហមេធាវីការពារក្តី ក៏បានលើកឡើងអំពីសុពលភាពនៃការបោះបង់សិទ្ធិមានមេធាវី។

២៨. យោងតាមការវិនិច្ឆ័យមុនៗ នៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាសម្រេចឃុំខ្លួន ឌុច បណ្តោះអាសន្ន[៣] ជាពិសេសបន្ទាប់ពីធ្វើការពិចារណាមាត្រា ២៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា[៤] អង្គបុរេជំនុំជម្រះបានធ្វើការពិនិត្យនិយ័តភាពនៃកិច្ចដំណើរការនីតិវិធី នៅមុនពេលចេញដីកា។[៥]

២៩. នៅក្នុងសេចក្តីសម្រេច លើបណ្តឹងឧទ្ធរណ៍សម្រេចឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ និងបន្ទាប់ពីបានធ្វើការពិនិត្យកាលៈទេសៈនៃការបង្ហាញខ្លួនលើកដំបូង និងសវនាការតទល់គ្នា អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា "នៅពេលពិចារណាលក្ខខណ្ឌតម្រូវនៃការបោះបង់សិទ្ធិ និងកាលៈទេសៈនៃរឿងក្តីនេះ ការបោះបង់សិទ្ធិរបស់ជនត្រូវចោទ

[៣] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំចំពោះដីកាសម្រេចឃុំខ្លួន កាំង ហ្កេចអ៊ាវ ហៅ "ឌុច" បណ្តោះអាសន្ន ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧ C5/45 វាក្យខណ្ឌទី៧ និងវាក្យខណ្ឌទី៨។

[៤] មាត្រា ២៦១ (ការពិនិត្យលើនិយ័តភាពនៃនីតិវិធី)

នៅរាល់ពេលដែលទទួលបានពាក្យបណ្តឹង សភាស៊ើបសួរពិនិត្យមើលពីនិយ័តភាពនៃនីតិវិធី និងការប្រព្រឹត្តទៅដ៏ល្អនៃនីតិវិធីនេះ។

កាលណាពិនិត្យឃើញថាមូលហេតុនៃមោឃភាព សភាស៊ើបសួរអាចចាត់ទុកជាមោឃៈ ដោយឯកឯង នូវនីតិវិធីទាំងមូល ឬផ្នែកណាមួយ។ សភាស៊ើបសួរត្រូវធ្វើដូចដែលមានចែងនៅក្នុងមាត្រា ២៨០ (អានុភាពនេះមោឃភាពកម្ម)នៃក្រមនេះ។

[៥] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំចំពោះដីកាសម្រេចឃុំខ្លួន នួន ជា បណ្តោះអាសន្ន ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ C11/54 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំចំពោះដីកាសម្រេចឃុំខ្លួន នួន ជា បណ្តោះអាសន្ន") វាក្យខណ្ឌទី៩ ។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

D55/I/8



មានលក្ខណៈច្បាស់លាស់ និងធ្វើឡើងដោយស្ម័គ្រចិត្ត ហេតុដូច្នេះហើយ វាមានលក្ខណៈត្រឹមត្រូវ។”[៦]

៣០. ដោយសារសហមេធាវីការពារក្តីមិនបានលើកឡើងនូវអំណះអំណាងថ្មីៗចំពោះករណីនេះ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ពាក់ព័ន្ធនឹងការបង្ហាញខ្លួនលើកដំបូង និងសវនាការសួរតទល់គ្នា ពាក្យសុំមោឃភាពនេះត្រូវបានសម្រេចនៅក្នុងបណ្តឹងឧទ្ធរណ៍ឃុំខ្លួនបណ្តោះអាសន្នរួចហើយ។ ដូច្នេះ ដោយសារពាក្យសុំនេះលើកឡើងអំពីបញ្ហាទាំងនេះ ពាក្យសុំនេះមិនអាចទទួលយកបានឡើយ។

៣១. ករណីនេះបណ្តាលឱ្យពាក្យសុំដែលពាក់ព័ន្ធនឹងមោឃភាពនៃការស៊ើបអង្កេត និងកិច្ចស៊ើបសួរដែលបានធ្វើឡើងនៅក្នុងការសួរយកចម្លើយថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៧ ទទួលយកបាន នៅចំពោះមុខអង្គបុរេជំនុំជម្រះ។

## ២. មូលដ្ឋាននៃមោឃភាពនីតិវិធី

៣២. អង្គបុរេជំនុំជម្រះនឹងធ្វើការពិនិត្យមូលដ្ឋាននៃមោឃភាពនីតិវិធី ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង។ បន្ថែមទៅលើចំនុចច្បាប់ដែលលើកឡើងខាងក្រោម អង្គបុរេជំនុំជម្រះបានធ្វើការពិចារណាក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា យុត្តិសាស្ត្រអន្តរជាតិ និង ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ក្រោយពីពិចារណាចំនុចជាក់លាក់នៃប្រព័ន្ធមោឃភាព។

៣៣. មូលដ្ឋានចំពោះមោឃភាពនីតិវិធីមានចែងនៅក្នុងវិធាន ៤៨ នៃវិធានផ្ទៃក្នុង:

កិច្ចស៊ើបសួរ ឬ កិច្ចរបស់អង្គជំនុំជម្រះអាចត្រូវបានចាត់ទុកជាមោឃៈតែចំពោះករណីមិនគោរពវិធានបញ្ញត្តិដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំប៉ុណ្ណោះ។

---

[៦] សាលដីកាលើបណ្តឹង ឧទ្ធរណ៍ប្រឆាំចំពោះដីកាសម្រេចឃុំខ្លួន នួន ជា បណ្តោះអាសន្ន វាក្យខណ្ឌទី៣៩។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C. ១០

៣៤. ដូច្នេះ វាត្រូវតែមានៈ (១) វត្តមាននៃមោឃភាពនីតិវិធី។ និង(២) នៅពេលមានវិការភាពនៃនីតិវិធី កំហុសនីតិវិធីនេះ ដាច់ខាតបង្កើតជាការរំលោភសិទ្ធិរបស់ភាគីដែលបានដាក់ពាក្យសុំ។

៣៥. វិធាន ៧៦(២) នៃវិធានផ្ទៃក្នុង ដូចមានចែងនៅក្នុងវាក្យខណ្ឌទី ១៩ ខាងលើចែងថា ភាគីដែលដាក់ពាក្យសុំមានកាតព្វកិច្ច លើកឡើងអំពីមោឃភាពនៃផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធី និងមានកាតព្វកិច្ចផ្តល់ហេតុផល។ នៅក្នុងវិធានផ្ទៃក្នុង មិនមានបទប្បញ្ញត្តិដែលចែងថា អង្គបុរេជំនុំជម្រះអាចធ្វើការប្រកាសមោឃភាពនៃកិច្ចស៊ើបសួរ តាមគំនិតផ្តួចផ្តើមរបស់ខ្លួនឡើយ។ ដូច្នេះ អង្គបុរេជំនុំជម្រះមានសមត្ថកិច្ចលើតែពាក្យសុំរបស់ភាគីដែលបានដាក់ជូនតែប៉ុណ្ណោះ។

៣៦. អង្គបុរេជំនុំជម្រះសង្កេតឃើញថា វិធាន ៤៨ នៃវិធានផ្ទៃក្នុងជាភាសាបារាំង ក៏ដូចជាក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាជាភាសាខ្មែរ បារាំង និងអង់គ្លេសដែរ (គឺមាត្រា ២៥២) មិនបានលើកឡើងអំពីការរំលោភសិទ្ធិទាំងឡាយឡើយ ប៉ុន្តែបានចែងអំពីផលប្រយោជន៍ដែលបានប៉ះពាល់។ ដោយធ្វើការពិនិត្យមើលសេចក្តីណែនាំនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា អង្គបុរេជំនុំជម្រះនឹងធ្វើការបកស្រាយថា "ការរំលោភសិទ្ធិទាំងឡាយ" ជា "ផលប្រយោជន៍ដែលបានប៉ះពាល់"។

៣៧. ចំពោះកំហុសនីតិវិធីមួយចំនួន បញ្ហាមោឃភាពត្រូវបានចែងនៅក្នុងបទប្បញ្ញត្តិមួយចំនួនដែលពាក់ព័ន្ធ។ ចំពោះករណីនេះ វិធាន ៥៣(៣) នៃវិធានផ្ទៃក្នុងចែងថា "អវត្តមានផ្នែកណាមួយនៃទម្រង់ការខាងលើនេះ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដូចមានចែងក្នុងអនុវិធាន ១ ត្រូវចាត់ទុកជាមោឃៈ។" វិធាន ៦៧ នៃវិធានផ្ទៃក្នុង ស្តីពីដីកាដំណោះស្រាយចែងថា"ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះត្រូវបញ្ជាក់អំពីអត្តសញ្ញាណនៃជនជាប់ចោទ ការបង្ហាញអំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើសដោយសហចៅក្រមស៊ើបអង្កេត ក្នុងនោះមានទាំងបទប្បញ្ញត្តិនៃបទឧក្រិដ្ឋដែលពាក់ព័ន្ធ និងប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ បើពុំនោះសោតដីកានេះត្រូវ ចាត់ទុកជាមោឃៈដោយកំហុសនីតិវិធី។"



អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C * C.E.T.C

D55/I/8



៣៨. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា សម្រេចជាឯកច្ឆ័នថា "ច្បាប់អន្តរជាតិមានចែងអំពីសិទ្ធិទទួលបានដំណោះស្រាយដ៏មានប្រសិទ្ធិភាពចំពោះការរំលោភសិទ្ធិរបស់ជនជាប់ចោទ ដូចដែលចែងនៅក្នុងមាត្រា ២(៣)(ក) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ"។[៧]

៣៩. មាត្រា ២(៣)(ក) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ("ICCPR") ចែងថា:

> ៣. រដ្ឋជាភាគីនៃកតិកាសញ្ញានេះ ត្រូវមានភារៈកិច្ចៈ
>
> (ក) ត្រូវធានាថា បើមានការរំលោភលើសិទ្ធិ ឬសេរីភាពរបស់ពលរដ្ឋណាម្នាក់ រដ្ឋត្រូវមានភារៈកិច្ចរកវិធីដោះស្រាយបញ្ហានេះឱ្យបានសក្តិសិទ្ធិ ទោះបីការរំលោភនោះបានប្រព្រឹត្តឡើងដោយភ្នាក់ងារ ដើម្បីបំពេញបេសកកម្មជាផ្លូវការក៏ដោយ។

៤០. អង្គបុរេជំនុំជម្រះយល់ឃើញថា ការបង្ហាញអំពីការរំលោភសិទ្ធិរបស់ជនត្រូវចោទ ដែលត្រូវបានទទួលស្គាល់នៅក្នុង ICCPR អាចបង្គ្រប់ជាកំហុសនីតិវិធី ហើយនឹងប៉ះពាល់ដល់ផលប្រយោជន៍របស់ជនត្រូវចោទ។ នៅក្នុងករណីបែបនេះ កិច្ចស៊ើបសួរ ឬកិច្ចរបស់តុលាការអាចចាត់ទុកថាមោឃៈ។

៤១. នៅពេលមានការរំលោភសិទ្ធិក្នុងអំឡុងពេលប្រមូលភស្តុតាង ភស្តុតាងទាំងនោះ នៅក្នុងច្បាប់ជាតិ និងអន្តរជាតិ មិនត្រូវបានចាត់ទុកថាមិនអាចទទួលយកបានដោយស្វ័យប្រវត្តិនោះទេ។ "ប៉ុន្តែ [...] វិធីសាស្ត្រ និងកាលៈទេសៈជុំវិញការប្រមូលភស្តុតាង ភាពជឿជាក់របស់ភស្តុតាងនោះ ព្រមទាំងផលប៉ះពាល់លើផលប្រយោជន៍នៃកិច្ចដំណើរការនីតិវិធី នឹងសម្រេចពីភាព

---

[៧] *Rwamakuba ទល់នឹង រដ្ឋអាជ្ញា* ICTR-98-44C-A សាលដីកាលើបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចលើដំណោះស្រាយសមស្រប អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៧ វាក្យខណ្ឌទី២៥។ សូមអានផងដែរ *Barayagwiza ទល់នឹង រដ្ឋអាជ្ញា* ICTR-97-19-AR72 សាលដីកា (សំណើរបស់រដ្ឋអាជ្ញាសុំពិនិត្យឡើងវិញឬពិចារណាឡើងវិញ) អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០០ វាក្យខណ្ឌទី៧៤។ *Rwamakuba តទល់នឹង រដ្ឋអាជ្ញា* ICTR-98-44-A សាលដីកា (បណ្តឹងឧទ្ធរណ៍ចំពោះការលើកចោលសំណើស្តីពីការចាប់ខ្លួននិងឃុំខ្លួនខុសច្បាប់) អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០១។ *Kajelijeli ទល់នឹង រដ្ឋអាជ្ញា* ICTR-98-44A-A សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៥ វាក្យខណ្ឌទី២៥៥។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

ដែលអាចទទួលយកភស្តុតាងនោះ។"[៨] អង្គបុរេជំនុំជម្រះយល់ឃើញថា ខ្លួនត្រូវពិចារណាកត្តាទាំងនេះ នៅពេលពិចារណាថា បញ្ហាមោឃភាពនីតិវិធី គឺជាដំណោះស្រាយដ៏មានប្រសិទ្ធិភាពចំពោះការរំលោភបំពាន ។

៤២. ជាចុងក្រោយ នៅក្នុងករណីបទប្បញ្ញត្តិដែលពាក់ព័ន្ធមិនមានចែងអំពីមោឃភាពនៃកំហុសនីតិវិធី និងក្នុងករណី ICCPR មិនបានទទួលស្គាល់អំពីការរំលោភលើសិទ្ធិ ភាគីដែលដាក់ពាក្យសុំនឹងត្រូវបង្ហាញថា ផលប្រយោជន៍របស់ខ្លួនត្រូវបានប៉ះពាល់ដោយសារកំហុសនីតិវិធី។

## ៣. មូលដ្ឋានលើមោឃភាពដែលបានស្នើសុំ

៤៣. ជាបឋម អង្គបុរេជំនុំជម្រះនឹងធ្វើការពិនិត្យមូលដ្ឋានដែលការសួរយកចម្លើយមិនបានរៀបចំឱ្យបានត្រឹមត្រូវ។

៤៤. នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់សហព្រះរាជអាជ្ញាថា សហចៅក្រមស៊ើបអង្កេតនឹងធ្វើការរៀបចំការសួរយកចម្លើយជនត្រូវចោទ។ សហចៅក្រមស៊ើបអង្កេតបានកោះហៅសហមេធាវីការពារក្តីជាតិគឺលោក សុន អារុណ ឱ្យមកចូលរួមក្នុងការសួរយកចម្លើយនេះ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ជនត្រូវចោទនៅពេលនោះ មានសហមេធាវីការពារក្តីជាតិរបស់ខ្លួនតែម្នាក់គត់ធ្វើជាតំណាងការពារ ដោយសារជនត្រូវចោទមិនទាន់បានជ្រើសរើសសហមេធាវីបរទេសរបស់ខ្លួននៅឡើយ មុនថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៧។

[៨] *រដ្ឋអាជ្ញា តទល់នឹង Brdjanin* IT-99-36-T សេចក្តីសម្រេចលើការ"បដិសេធរបស់មេធាវីការពារចំពោះការទទួលយកភស្តុតាង" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៣ វាក្យខណ្ឌទី៥៥។

00219347

D55/I/8



៤៥. នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៧ សហមេធាវីការពារក្ដីជាតិ បានស្នើសុំការពន្យារពេលសួរយកចម្លើយដោយសម្អាងថា មេធាវីការពារក្ដីមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការត្រៀមខ្លួនការពារក្ដី។[៩] សំណើនេះត្រូវបានសហចៅក្រមស៊ើបអង្កេតបដិសេធចោល។[១០]

៤៦. សិទ្ធិមានពេលវេលាគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការពារក្ដីមានចែងនៅក្នុងមាត្រា ៣៥ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ដោយយោង និងអនុលោមតាមមាត្រា ១៤ នៃកតិកាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។

៤៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សិទ្ធិជាមូលដ្ឋាននេះគឺសិទ្ធិទទួលបាន"ការជំនុំជម្រះដោយយុត្តិធម៌" ដោយមានគោលបំណងផ្ដល់ដល់ជនត្រូវចោទនូវពេលវេលាគ្រប់គ្រាន់ក្នុងការត្រៀមខ្លួនសម្រាប់ការជំនុំជម្រះ។ គោលបំណងនៃការសួរយកចម្លើយគឺដើម្បីសួរសំនួរអំពីអ្វីដែលជនត្រូវចោទដឹងដោយផ្ទាល់ ប៉ុន្តែមិនមែនដើម្បីឆ្លើយតបចំពោះការចោទប្រកាន់លើគាត់ឡើយ។ ជនត្រូវចោទអាចប្រើប្រាស់សិទ្ធិរបស់គាត់នៅស្ងៀមមិននិយាយស្ដី ហើយក្នុងករណីគាត់ប្រើសិទ្ធិនេះ គឺគាត់រារាំងការផ្ដល់ភស្តុតាងដាក់បន្ទុកមកលើគាត់។ ដូច្នេះ សិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ក្នុងការត្រៀមខ្លួនសម្រាប់ការជំនុំជម្រះ មិនអនុវត្តចំពោះការត្រៀមខ្លួនក្នុងការសួរយកចម្លើយឡើយ។

៤៨. វិធាន ៥៨(១) នៃវិធានផ្ទៃក្នុងចែងថា:

> នៅពេលជនត្រូវចោទមានមេធាវី សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាកោះហៅមេធាវីយ៉ាងតិចបំផុត ៥ (ប្រាំ)ថ្ងៃមុនពេលធ្វើការសួរចម្លើយ។ ក្នុងអំឡុងពេលនេះ មេធាវីអាចពិនិត្យមើលសំណុំរឿងបាន។

៤៩. អង្គបុរេជំនុំជម្រះយល់ឃើញថា បទប្បញ្ញត្តិនេះមានន័យថា សហមេធាវីការពារក្ដី យ៉ាងហោចណាស់ មានរយៈពេលប្រាំ(៥)ថ្ងៃ ក្នុងការត្រៀមខ្លួនសម្រាប់ការសួរយកចម្លើយ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីការពារក្ដីជាតិត្រូវបានកោះហៅ ដោយ

---

[៩] ពាក្យសុំពន្យារពេលសវនាការ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៧ D23 វាក្យខណ្ឌទី ២។

[១០] កំណត់ហេតុសួរយកចម្លើយជនត្រូវចោទ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៧ D23 វាក្យខណ្ឌទី២។



ចៅក្រមជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

D55/I/8



អនុលោមទៅតាមបទប្បញ្ញត្តិនេះ ហេតុដូច្នេះហើយ សហមេធាវីការពារក្តីទទួលបានរយៈពេលនេះក្នុងការត្រៀមខ្លួនសម្រាប់ការសួរយកចម្លើយ។

៥០. ចំពោះករណីត្រៀមខ្លួនសម្រាប់ការសួរយកចម្លើយ ដូចដែលសហមេធាវីការពារក្តីបានលើកឡើង អង្គជំនុំជម្រះមិនឃើញមានកំហុសនីតិវិធីឡើយ ។

៥១. ចំនុចទីពីរ អង្គបុរេជំនុំជម្រះនឹងធ្វើការពិនិត្យថាតើ ជនត្រូវចោទ "តាមរយៈការផ្តល់សញ្ញាថាគាត់មិនមានជំហរក្នុងការចូលរួមយ៉ាងមានប្រសិទ្ធិភាពក្នុងកិច្ចដំណើរការនីតិវិធី"[១១] បានប្រើប្រាស់សិទ្ធិនៅស្ងៀមមិននិយាយស្តីពិតប្រាកដមែនដែរឬទេ។

៥២. កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការសួរយកចម្លើយបង្ហាញដូចខាងក្រោមនេះ៖

"**ការសួរចម្លើយ**

**សំនួរ-ឆ្លើយ**

**លោកមេធាវី សុន អារុណ (សអ):** ខ្ញុំសូមឱ្យលើកពេលនៃការសួរចម្លើយនេះ ហើយខ្ញុំដាក់ពាក្យរួចហើយអំពីការនេះ ប៉ុន្តែខ្ញុំនឹងគោរពតាមអំពីសេចក្តីសម្រេចរបស់លោកចៅក្រមស៊ើបអង្កេត អំពីបញ្ហានេះ។

**សហចៅក្រមស៊ើបអង្កេត:** ថិរវេលាដែលមានចែងនៅក្នុងវិធាន ៥៨(១) នៃវិធានផ្ទៃក្នុង ត្រូវបានគោរពត្រឹមត្រូវហើយ ដូច្នេះ ការសួរចម្លើយថ្ងៃនេះត្រូវរក្សាទុកដដែល។

**សំនួរលោក យបឡូ និង មឡូ:** នៅមុនពេលវាយបែកភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ តើលោកមានការទទួលខុសត្រូវនយោបាយអ្វីខ្លះ តើលោកមានតួនាទីនិងសកម្មភាពអ្វីខ្លះ?

**ឆ្លើយ:** ខ្ញុំសុំប្រាប់លោកថាសុខភាពខ្ញុំមិនល្អទេ ហើយ ខ្ញុំគេងមិនសូវលក់ទេយប់មិញ ហើយ សម្ពាធឈាមឡើងដល់ ១៦ ១៧ ១៨។ ដូច្នេះ ខួរក្បាលខ្ញុំមិនធម្មតា។ ដូច្នេះ សុំឱ្យលោកចៅក្រម ពិចារណាអំពីបញ្ហានេះ។

**សំនួរលោក មឡូ:** តើលោកមានការទទួលខុសត្រូវនយោបាយអ្វីខ្លះ តើលោកមានតួនាទីនិងសកម្មភាពអ្វីខ្លះ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥?

**ឆ្លើយ:** ខ្ញុំជាប្រធានសភាប្រជាជន។

**សំនួរលោក មឡូ:** តើចាប់ពីពេលណាមក?

**ឆ្លើយ:** ខ្ញុំមិនចាំទេ។ បើលោកចៅក្រមទុកពេលឱ្យខ្ញុំសម្រាកសិន ខ្ញុំអាចបំភ្លឺជូនតុលាការនាពេលក្រោយ។"[១២]

---

[១១] ពាក្យសុំឱ្យអង្គបុរេជំនុំជម្រះទទួលយករឿងក្តីមកជំនុំជម្រះដើម្បីប្រកាសមោឃភាពកិច្ចដំណើរការនីតិវិធី D55 វាក្យខណ្ឌទី១១។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

៥៣. កំណត់ហេតុនៃការសួរយកចម្លើយផ្នែកបន្ទាប់ពីនេះលើកឡើងពីការពិភាក្សាលើស្ថានភាពសុខភាពរបស់ជនត្រូវចោទ។

៥៤. កំណត់ហេតុនៃការសួរយកចម្លើយបានបញ្ជាក់ច្បាស់ថា សហមេធាវីការពារក្តីទាំងពីររបស់ជនត្រូវចោទ និងជនត្រូវចោទខ្លួនឯង បានស្នើសុំពន្យារពេលការសួរយកចម្លើយ។ សំណើនេះមិនអាចយល់ឃើញថាជាការព្យាយាមប្រើប្រាស់សិទ្ធិនៅស្ងៀមមិននិយាយស្តីនោះឡើយ។

៥៥. អង្គបុរេជំនុំជម្រះយល់ឃើញថា គ្មានកំហុសនីតិវិធី។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទៈ:**

១) បណ្តឹងឧទ្ធរណ៍អាចទទួលយកបានតាមទម្រង់។

២) ប្រកាសមិនទទួលយកពាក្យសុំមោឃភាព ដោយសារពាក្យសុំនេះជាប់ពាក់ព័ន្ធនឹងការបង្ហាញខ្លួនលើកដំបូង និងសវនាការសួរតទល់គ្នា។

៣) បដិសេធបណ្តឹងឧទ្ធរណ៍ដោយខុសនឹងគតិច្បាប់។

សាលដីកានេះបិទផ្លូវតវ៉ា អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង។

**ភ្នំពេញ ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨**

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

Rowan DOWNING ន័យ ថុល Katinka LAHUIS ហួត វុទ្ធី ប្រាក់ គឹមសាន

[១២] កំណត់ហេតុសួរយកចម្លើយជនត្រូវចោទ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៧ D23 វាក្យខណ្ឌទី២ និងវាក្យខណ្ឌទី ៣។